រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

# សេចក្តីសម្រេចលេខ ៥៦ សសរ

## ស្តីពីការបង្កើតគណៈកម្មការចំរុះពិភាក្សាជាមួយគណៈប្រតិភូ អគ្គនាយកដ្ឋានព្រំដែន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការចំរុះ ពិភាក្សាជាមួយគណៈប្រតិភូអគ្គនាយកដ្ឋានព្រំដែន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានសមាសភាពដូចតទៅ ៖

១-ឯកឧត្តម ព្រំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ ជាអនុប្រធាន

៣-ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤-ឯកឧត្តម នីយ ធឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក

៥-ឯកឧត្តម ហួន សារ៉េង សមាជិកគណៈកម្មការព្រំដែន សមាជិក

៦-លោក សត់ សេដ្ឋា អគ្គនាយករងរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៧-ឧត្តមសេនីយ៍ទោ ឈុំ សុជាតិ នាយកទីចាត់ការព្រំដែន(ក.ឋ.ខ.ភ) សមាជិក

៨-ឧត្តមសេនីយ៍ទោ គឹម អាន់ ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន សមាជិក

៩-ឧត្តមសេនីយ៍ត្រី គីត លឹមហៃ ប្រធាននាយកដ្ឋានបច្ចេកទេសនគរបាលព្រំដែន សមាជិក

១០-ឧត្តមសេនីយ៍ត្រី ចាន់ អ៊ិន ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក សមាជិក

១១-វរសេនីយ៍ឯក ម៉ៅ សាគុណ អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនទឹក សមាជិក

**ប្រការ ២ :** គណៈកម្មការចំរុះមានភារកិច្ច ៖

-ស្រាវជ្រាវរកឯកសារពាក់ព័ន្ធនឹងបញ្ហាព្រំដែនគោក និងព្រំដែនទឹករវាងកម្ពុជា និងវៀតណាម ។

-ប្រជុំពិភាក្សាត្រៀមខ្លឹមសារពាក់ព័ន្ធ នឹងសហប្រតិបត្តិការតាមព្រំដែន ដើម្បីជួបពិភាក្សាធ្វើការងារជាមួយគណៈប្រតិភូអគ្គនាយកដ្ឋានព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**ប្រការ ៣ :** គណៈកម្មការចំរុះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ របស់អនុប្រធានក្នុងករណីប្រធានអវត្តមាន ហើយត្រូវរាយការណ៍លទ្ធផលការងាររបស់ខ្លួនជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** គណៈកម្មការចំរុះនេះ នឹងត្រូវរំសាយក្រោយពេលជួបពិភាក្សាជាមួយគណៈប្រតិភូ អគ្គនាយកដ្ឋានព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវបានបញ្ចប់ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៧ សសរ
## ស្តីពីការបង្កើតក្រុមការងារមួយទទួលបន្ទុកសិក្សាកសាងទីក្រុងពិសេសមួយនៅប្រជុំកោះរុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល